វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១២ លេខ ០៣

## លើកកម្ពស់មធ្យោបាយតភ្ជាប់គ្នាក្នុងតំបន់ ដើម្បីកំណើនសេដ្ឋកិច្ច៖ កម្ពុជា និង អាស៊ាន ឆ្នាំ២០១២[១]

"ខ្ញុំសូមលើកទឹកចិត្ត និងជំរុញដល់ ស្ថាប័នសិក្សាស្រាវជ្រាវក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ សមាគមពាណិជ្ជកម្ម និង ឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា ឲ្យចូលរួមជាមួយរដ្ឋាភិបាលបណ្តាប្រទេសអាស៊ាន ដើម្បីបង្កើនកិច្ចប្រឹងប្រែងរួមគ្នាបង្កើតមូលដ្ឋានផលិតកម្ម និងទីផ្សារអាស៊ានដែលបានធ្វើសមាហរណកម្មពេញលេញ បញ្ចូលគ្នាតែមួយ សំដៅជំរុញវិបុលភាពអាស៊ាន។"

*ឯកឧត្តម ចម ប្រសិទ្ធ*
*ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម នៃរាជរដ្ឋាភិបាលកម្ពុជា*

### កំណើនសេដ្ឋកិច្ចក្នុងតំបន់ និងអាស៊ាន

ឆ្នាំនេះ ប្រទេសកម្ពុជាដល់វេណធ្វើជាប្រធានអាស៊ានជាលើកដំបូង គិតចាប់ពីឆ្នាំ២០០២ មក។ ឋានៈជាប្រធានអាស៊ាននេះ នឹងផ្តល់ឱកាសសម្រាប់ឲ្យកម្ពុជាកំណត់ទ្រង់ទ្រាយ នៃស្ថាប័នដ៏មានឥទ្ធិពលខ្លាំងបំផុតមួយនៅក្នុងតំបន់។ គោលដៅសំខាន់បំផុត គឺការកសាងទំនាក់ទំនងបន្ថែម និងបំបាត់ឧបសគ្គរាំងកំណើនកិច្ចសហប្រតិបត្តិការផ្ទៃក្នុងអាស៊ាន ហើយនិងការពង្រឹងទំនាក់ទំនងជាមួយដៃគូពីខាងក្រៅ។

ទំនាក់ទំនងផ្សេងៗក្នុងក្របខ័ណ្ឌអាស៊ាន កាន់តែសំខាន់ខ្លាំងឡើង ស្របពេលដែលតំបន់នេះ បានចូលដល់ដំណាក់កាលនៃការផ្លាស់ប្តូរឆាប់រហ័ស និងការរៀបបចំទម្រង់សេដ្ឋកិច្ចសាកលឲ្យមានតុល្យភាពឡើងវិញ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធយ៉ាងជ្រាលជ្រៅ កំពុងកើតមានឡើង ហើយតំបន់អាស៊ីកំពុងក្លាយជា ក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចពិភពលោក។

តំបន់កំណើនសេដ្ឋកិច្ចអាស៊ី បានផ្តល់ឱកាសថ្មីៗសម្រាប់ទូទាំងតំបន់នៅចំពេលដ៏តឹងតែងមួយ។ វិបត្តិបំណុលរដ្ឋ និងកំណើនអន់ខ្សោយនៅបណ្តាប្រទេសសេដ្ឋកិច្ចជឿនលឿន កំពុងកាត់បន្ថយតម្រូវការក្នុងពិភពលោក និងឱកាសមានកំណើន។ ប៉ុន្តែកំណើនកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ក្នុងតំបន់ នឹងបង្កើតជាចំណងទាក់ទងពាណិជ្ជកម្ម ព្រមទាំងប្រភពតម្រូវការបន្ថែមពី ប្រទេសមានសេដ្ឋកិច្ចធំៗ និងលូតលាស់លឿនបំផុតនៅលើពិភពលោក។

សេដ្ឋកិច្ចអាស៊ាន បានថយចុះការពឹងពាក់ផ្នែកពាណិជ្ជកម្មលើតំបន់អឺរ៉ុប ប្រទេសជប៉ុន និងសហរដ្ឋអាមេរិក និងកំពុងស្វែងរកកាន់តែខ្លាំងនូវទីផ្សារនាំចេញនៅក្បែរៗខ្លួនវិញ។

នៅទសវត្សរ៍ចុងក្រោយនេះ ពាណិជ្ជកម្មផ្ទៃក្នុងអាស៊ាន បានរីកលូតលាស់គួរឲ្យកត់សម្គាល់ ទោះបីមានការប្រកួតប្រជែងពីប្រទេសចិន និងប្រទេសសេដ្ឋកិច្ចឧស្សាហកម្មថ្មីៗក្តី (រូបភាព ១)។ នាបច្ចុប្បន្ន ពាណិជ្ជកម្មផ្ទៃក្នុង អាស៊ាន ៥ មានចំណែក ២៤% នៃពាណិជ្ជកម្មសរុបជាមួយប្រទេសឯទៀតនៅអាស៊ី (ក្រៅពីប្រទេសជប៉ុន)។

អាស៊ាន ក៏បានផ្តល់ជាវេទិកាដ៏មានប្រសិទ្ធភាពមួយដែរ សម្រាប់ឲ្យប្រទេសជាសមាជិក ធ្វើការតភ្ជាប់ទំនាក់ទំនងជាមួយ ប្រទេសមានសេដ្ឋកិច្ចសំខាន់ជាយុទ្ធសាស្ត្រផ្សេងៗទៀត។ អាស៊ាន បានចូលរួមយ៉ាងសកម្ម ក្នុងការលើកកម្ពស់ចំណងទាក់ទងជាមួយប្រទេសជាដៃគូ

រូបភាព១៖ លំហូរពាណិជ្ជកម្មផ្ទៃក្នុងអាស៊ាន ៥ (ពាន់លានដុល្លារ)




ប្រភព៖ បទបង្ហាញរបស់ លោក Aninda Mitra ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

---

១ អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ បកស្រាយដោយ ឯ.ឧ. ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃរាជរដ្ឋាភិបាលកម្ពុជា លោក Aninda Mitra ប្រធានសេដ្ឋវិទូប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងផ្នែកពាក់ព័ន្ធខ្លះៗដកស្រង់ចេញពី សុន្ទរកថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

* ផលិតផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១២:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

រូបភាព ២៖ ភាពខុសប្លែកគ្នារវាងចំណែកនៃការនាំចេញទៅកាន់ប្រទេសសេដ្ឋកិច្ចជឿនលឿននានា (សហភាពអឺរ៉ុប ជប៉ុន សហរដ្ឋអាមេរិក) និង ប្រទេសនៅអាស៊ី (មិនរាប់បញ្ចូល ជប៉ុន)




ប្រភព៖ បទបង្ហាញរបស់ លោក Aninda Mitra ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

ឯទៀតនៅអាស៊ី ហើយតាមរយៈនេះ បានផ្តល់ជាស្រទាប់ការពារមួយ ទល់នឹងវិបត្តិផ្សេងៗដែលប៉ះទង្គិចដល់ទីផ្សារនាំចេញជាប្រពៃណីពីរ គឺ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

រូបភាព ២ បង្ហាញពីនិន្នាការផ្លាស់ប្តូរយ៉ាងច្បាស់ពីទីផ្សារនាំចេញជាប្រពៃណីទៅកាន់ប្រទេសសេដ្ឋកិច្ចជឿនលឿន ទៅរកប្រភពតម្រូវការថ្មីៗនៅអាស៊ី។ ដោយឡែក កំណើនសេដ្ឋកិច្ចនៅអាស៊ាន និងបណ្តាប្រទេសទើបធ្វើឧស្សាហកម្មថ្មីៗ ឥឡូវនេះពឹងផ្អែកកាន់តែធំឡើងលើការនាំចេញទៅកាន់ប្រទេសអាស៊ីនានា។

## ពាណិជ្ជកម្ម វិនិយោគ និងលំហូរផ្ទៃក្នុងអាស៊ាន

គេតែងនិយាយថា មូលដ្ឋានគ្រឹះមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច គឺការលុបបំបាត់គម្លាតភូមិសាស្ត្រ និងពេលវេលា រវាងសេវាកម្ម ដំណើការផលិតកម្ម និងទីផ្សារ។

តួយ៉ាង កសិករម្នាក់នៅខេត្តមណ្ឌលគិរី ត្រូវជួបកំហិតក្នុងការបង្កើតមូលធន ប្រសិនបើឱកាសទីផ្សារមានតែនៅក្នុងភូមិគាត់។ បណ្តាញដឹកជញ្ជូនប្រសើរឡើង វាជួយកាត់បន្ថយពេលវេលា ចម្ងាយ និងថ្លៃដឹកជញ្ជូនពីកសិដ្ឋានទៅទីផ្សារនានាក្នុងប្រទេស។ ឆ្លងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ផលិតផលនានាអាចផ្គត់ផ្គង់ទៅឲ្យទីផ្សារក្នុងតំបន់ និងលើពិភពលោក ហើយតាមរយៈនេះ អាចជួយពង្រីកទំហំអាជីវកម្ម វិនិយោគ និងបង្កើនផលិតភាព។

ភាពតភ្ជាប់ទំនាក់ទំនងក្នុងតំបន់ សំដៅជាចម្បងលើការកាត់បន្ថយចម្ងាយ និងពេលវេលា ទាំងផ្ទៃក្នុងអាស៊ាន និងរវាងប្រទេសសមាជិកអាស៊ាន និងទីផ្សារពិភពលោក តាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងដឹកជញ្ជូន ព្រមទាំងការបំបាត់ឧបសគ្គផ្សេងៗខាងគោលនយោបាយ និងស្ថាប័ន ដែលរារាំងកំណើនអន្តរកម្មផ្នែកសេដ្ឋកិច្ចសង្គមកិច្ច។

អាស៊ាន បានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការលុបបំបាត់របាំងខាងស្ថាប័ន និងគោលនយោបាយ ចំពោះពាណិជ្ជកម្មរវាងបណ្តាប្រទេសជាសមាជិក។ ការលុបបំបាត់ពន្ធគយក្នុងតំបន់ ជាទិដ្ឋភាពដ៏សំខាន់នៃកំណែទម្រង់ទាំងនេះ ហើយនៅថ្ងៃទី១ មករា ២០១០ អាស៊ាន ៦ (ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) បានលុបពន្ធនាំចូលលើ ផលិតផលមានប្រភពនៅក្នុងអាស៊ានអស់ ៩៩,៦៥% នៃមុខផលិតផលជាប់ពន្ធ។ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម បានបន្ថយពន្ធគយមកត្រឹម ០-៥% លើ ៩៨,៨៦% នៃមុខផលិតផលជាប់ពន្ធ។

នីតិវិធីឆ្លងកាត់ព្រំដែនស្មុគស្មាញ និងគ្មានប្រសិទ្ធភាព ត្រូវបានកាត់តម្រឹមជាថ្មី តាមការបង្កើតសេវាពន្ធគយច្រកចេញចូលអាស៊ានតែមួយ (ASW)។ ពាណិជ្ជករមិនចាំបាច់ចំណាយពេល ប្រាក់កាស និងជួបការលំបាកស្មុគស្មាញច្រើន ដើម្បីទទួលបានសំណុំបែបបទពីស្ថាប័នជាច្រើនទៀតទេ គឺគ្រាន់តែស្នើសុំលិខិតអនុញ្ញាតដ៏ចាំបាច់ពីអាជ្ញាធរតែមួយកន្លែងបានហើយ។

អាស៊ាន បានអនុវត្តគម្រោងសាកល្បង ASW លើកទី១ រួចស្រេច ហើយបច្ចុប្បន្នកំពុងតែរៀបចំគម្រោងទី២។ កម្ពុជានឹងចាប់ផ្តើមសេវាច្រកចេញចូលតែមួយថ្នាក់ជាតិ (NSWs) នៅត្រីមាសទី៤ ឆ្នាំ២០១២ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការចូលរួមក្នុង ASW។

វិស័យសេវាកម្ម ជាពិសេសសេវាកម្មហិរញ្ញវត្ថុ ជាប្រភពសំខាន់មួយនៃកំណើនសេដ្ឋកិច្ចក្នុងទូទាំងតំបន់។ ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មក្នុងតំបន់ ប្រទេសទាំង ១០ ជាសមាជិក បានបំពេញតាមការសន្យានានា សម្រាប់កិច្ចព្រមព្រៀងក្របខ័ណ្ឌសេវាកម្មអាស៊ាន (AFAS) ដែលក្នុងនេះ មានទាំងការសន្យាបើកចំហច្រកចូលទីផ្សារសម្រាប់អនុវិស័យសេវាកម្មយ៉ាងហោចណាស់ ៦៥មុខ។

ការវិនិយោគផ្ទៃក្នុងតំបន់ កន្លងមកត្រូវបានសម្របសម្រួលដោយកិច្ចព្រមព្រៀងវិនិយោគគ្រប់ជ្រុងជ្រោយអាស៊ាន (ACIA) ដែលនឹងត្រូវអនុវត្តនៅត្រីមាសទី១ ឆ្នាំ២០១២។ ACIA ជាឯកសារវិនិយោគរួមមួយ ដែលគ្របដណ្តប់លើសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគនានា ដែលធ្វើឡើងដោយវិនិយោគិនក្នុងអាស៊ាន និងវិនិយោគិនបរទេសមានមូលដ្ឋានក្នុងអាស៊ាន។ ការបំបាត់នូវឧបសគ្គផ្នែកវិនិយោគនឹងទាក់ទាញវិនិយោគទុនកាន់តែច្រើន ជំរុញការប្រកួតប្រជែង និងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចប្រទេសនានាក្នុងតំបន់។

ចលនាបន្លាស់ទីនៃពលករជំនាញ ត្រូវតែជួយសម្រួលជាសំខាន់ ដើម្បីឲ្យស្របតាមសន្ទុះកំណើនសេដ្ឋកិច្ចក្នុងអាស៊ាន និងញ៉ាំងឲ្យកម្លាំងពលកម្មមានផលិតភាពខ្ពស់ជាអតិបរមា។ ដើម្បីសម្រេចគោលដៅនេះ អាស៊ាន បានអនុវត្តសេវាកម្មសម្រួលជំនាញវិជ្ជាជីវៈ ៧មុខ តាមរយៈកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមក (MRAs) ក្នុងផ្នែកវិស្វកម្ម ស្ថាបត្យកម្ម ការថែទាំអ្នកជម្ងឺ ឱសថ ទន្តពេទ្យវិទ្យា គណនេយ្យ និងការធ្វើអង្កេត។

អាស៊ាន ក៏កំពុងធ្វើបង្កើយនូវកិច្ចព្រមព្រៀងស្តីពី ចលនាផ្លាស់ទីនៃបុគ្គលរូបវន្តនៅក្នុងអាស៊ាន ដែលត្រូវដាក់អនុវត្តនៅខែសីហា ២០១២ ដើម្បីជួយសម្រួលចលនាប្រជាជន ដែលធ្វើពាណិជ្ជកម្មលើទំនិញ សេវាកម្ម និងវិនិយោគ។

កំណែទម្រង់គោលនយោបាយ ត្រូវបានបំពេញបន្ថែមដោយគំនិតផ្តួចផ្តើម សំដៅជំនះរបាំងរូបវន្តផ្សេងៗ រវាងប្រជាជាតិអាស៊ាននានា តាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង។ ប្រទេសសមាជិកអាស៊ាន ជាពិសេសប្រទេសមានសេដ្ឋកិច្ចលូតលាស់យឺត បានចូលរួមសកម្មក្នុងការកែលំអ និងកសាងផ្លូវថ្នល់ ផ្លូវដែក និងផ្លូវគមនាគមន៍ផ្សេងៗ ដើម្បីលើកកម្ពស់មធ្យោបាយតភ្ជាប់គ្នាចុះឡើងក្នុងតំបន់។

ជាក់ស្តែង ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង (រូបភាព ៣) ជាលទ្ធផលនៃកំណើនកិច្ចសហប្រតិបត្តិការ ក្នុងមហាអនុតំបន់មេគង្គ (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម)។ គំនិតផ្តួចផ្តើមនេះ រួមមានវិធានការច្រើនបែបយ៉ាង សំដៅលើកកម្ពស់ការភ្ជាប់ទំនាក់ទំនងផ្ទៃក្នុងអាស៊ាន ដូចជា ការកែលំអបណ្តាញផ្លូវថ្នល់ និងផ្លូវដែក រវាងកម្ពុជា

## រូបភាព ៣៖ ការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅតំបន់អាស៊ាន




ប្រភព៖ បទបង្ហាញរបស់ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

និងមណ្ឌលផលិតកម្មនានាក្នុងតំបន់ កិច្ចសហប្រតិបត្តិការផ្នែកអគ្គិសនីឆ្លងកាត់ព្រំដែន និងការបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធ ICT និងទូរគមនាគមន៍ក្នុងតំបន់។

គម្រោងឈានមុខគេ គឺការស្តារជួសជុលបណ្តាញផ្លូវដែកនៅកម្ពុជា ដែលគ្រោងចប់សព្វគ្រប់នៅឆ្នាំ២០១៣ ដោយមានផ្លូវដែកមេមួយខ្សែដំណើរការបានពេញលេញពីខេត្ត Kunming ទៅ សិង្ហបុរី។

## ការតភ្ជាប់អាស៊ាន ទៅនឹងបណ្តាញសេដ្ឋកិច្ចពិភពលោក

អាស៊ានដ៏រឹងមាំ ផ្តល់ឲ្យបណ្តាប្រទេសជាសមាជិកនូវវេទិកាមានប្រសិទ្ធភាពខ្ពស់សម្រាប់ការចូលរួមក្នុងទីផ្សារនៅអាស៊ី និងនៅតាមតំបន់ដទៃទៀត។ ជាក់ស្តែង កន្លងមកមានកិច្ចព្រមព្រៀងមួយចំនួនរួចហើយសម្រាប់ជួយសម្រួលឲ្យមានទំនាក់ទំនងសេដ្ឋកិច្ចកាន់តែច្រើន រវាងបណ្តាប្រទេសសមាជិកអាស៊ាន និងជាមួយប្រទេសសំខាន់ៗដទៃទៀតនៅលើពិភពលោក។

អាស៊ានបានចរចាលើ FTA ជាច្រើនដែលអាចជួយលើកកម្ពស់លទ្ធភាពនាំចេញរបស់ប្រទេសជាសមាជិក។ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ជាង ៩០% នៃមុខផលិតផលជាប់ពន្ធគយរបស់ អាស៊ាន ៦ និង ចិន អាចជួញដូរគ្នាបាន ដោយមិនជាប់ពន្ធគយ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) រវាង អាស៊ាន ៥ និង កូរ៉េ បានលុបពន្ធគយលើជិត ១០០% នៃមុខផលិតផលស្ថិតក្នុងរបបលុបពន្ធគយតាមល្បឿនធម្មតា។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-ញូវហ្ស៊ីលែន ដែលបានដាក់អនុវត្តក្នុងឆ្នាំ២០១២ គឺជាកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយជាងគេដែលបានធ្វើហើយមកទល់ពេលនេះ។

ក្របខ័ណ្ឌអាស៊ាន សម្រាប់ភាពជាដៃគូផ្នែកសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) សំដៅពង្រីក និងពង្រឹងទំនាក់ទំនងអាស៊ាន ជាមួយនឹងដៃគូពីខាងក្រៅផ្សេងទៀតដែលមិនគ្របដណ្តប់ដោយ FTAs ដោយដាក់បញ្ចូលនូវពាណិជ្ជកម្មសេវាកម្ម វិនិយោគ និងវិស័យផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច។ ភាពជាដៃគូផ្នែកសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន (AJCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា មានចែងពីវិធានការជាច្រើនសម្រាប់ជួយសម្រួលដល់ពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ។

ក្របខ័ណ្ឌ RCEP ដ៏ខ្លាំង ក៏ផ្តល់ផងដែរនូវយន្តការមួយសម្រាប់ឲ្យអាស៊ាន និងពួកដៃគូពីខាងក្រៅ ដោះស្រាយបញ្ហាខាងពាណិជ្ជកម្ម និងវិនិយោគ នៅពេលវាផុសឡើង។

នៅឯខាងក្រៅតំបន់អាស៊ី អាស៊ានបានព្យាយាមយ៉ាងសកម្មក្នុងការបង្កើតជាកិច្ចព្រមព្រៀងនានា ដើម្បីជំរុញអន្តរកម្មផ្នែកសេដ្ឋកិច្ច។ សេចក្តីប្រកាសរួមគ្នារវាងអាស៊ាន-កាណាដា ស្តីពីពាណិជ្ជកម្ម និងវិនិយោគ នឹងជំរុញវិស័យទាំងពីរនេះ តាមរយៈព្រឹត្តិការណ៍កសាងបណ្តាញអាជីវកម្មជាមួយអាជីវកម្ម និងការរៀបចំសន្និសីទកំពូលផ្នែកអាជីវកម្មអាស៊ាន-កាណាដា។ កិច្ចព្រមព្រៀងក្របខ័ណ្ឌ លើពាណិជ្ជកម្ម និងវិនិយោគ (TIFA) បានចុះហត្ថលេខាជាមួយសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៦។ ការរីកចម្រើនថ្មីៗទៀត រួមមាន ការរៀបចំវេទិកាពាណិជ្ជកម្ម និងបរិស្ថានអាស៊ាន-សហរដ្ឋអាមេរិក កម្មវិធីផ្សព្វផ្សាយ ASEAN Roadshow ទៅកាន់សហរដ្ឋអាមេរិក ការសន្ទនាតាមប្រព័ន្ធឌីហ្សីតាល់រវាងអាស៊ាន-សហរដ្ឋអាមេរិក និងវេទិកាសេវាថែទាំសុខភាពអាស៊ាន-សហរដ្ឋអាមេរិក។

ការសន្ទនាជាមួយសហភាពអឺរ៉ុប ក៏បានប្រសើរឡើងដែរ។ កិច្ចប្រជុំកំពូលផ្នែកអាជីវកម្មអាស៊ាន-សហភាពអឺរ៉ុប (AEBS) លើកទី១ បានប្រារព្ធឡើងដោយជោគជ័យកាលពីឆ្នាំមុន ហើយបច្ចុប្បន្នកិច្ចប្រជុំលើកទី២ បានគ្រោងឡើងរួចហើយ។ ម្យ៉ាងទៀត ការពិគ្រោះយោបល់រវាងបណ្តារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មសហភាពអឺរ៉ុប នឹងត្រូវធ្វើឡើងបន្តពីកិច្ចប្រជុំកំពូលអាស៊ាន លើកទី២០

នៅរាជធានីភ្នំពេញ ក្នុងខែមេសា ២០១២ ដោយផ្តល់ឱកាសឲ្យក្រុមហ៊ុននានា កសាងបណ្តាញ និងដោះស្រាយបញ្ហាសំខាន់ៗមួយចំនួន។

នាពេលថ្មីៗ អាស៊ានបានចាប់ផ្តើមកិច្ចសន្ទនាមួយជាមួយប្រទេសរុស្ស៊ី។ ការជួបប្រជុំលើកទី១ នៃក្រុមជំនាញការរួមគ្នាអាស៊ាន-រុស្ស៊ី បានធ្វើឡើងកាលពីខែតុលា ២០១១ នៅក្រុងភ្នំពេញ ដើម្បីរៀបចំផែនទីបង្ហាញផ្លូវ (roadmap) គ្រប់ជ្រុងជ្រោយមួយសម្រាប់ពង្រីកទំនាក់ទំនងពាណិជ្ជកម្ម និងសេដ្ឋកិច្ចអាស៊ាន-រុស្ស៊ី។

## ឆ្ពោះទៅបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥

បញ្ហាប្រឈមដ៏ធំសម្រាប់កម្ពុជា ក្នុងឋានៈជាប្រធានអាស៊ាន គឺធ្វើយ៉ាងណា ឲ្យអាស៊ានសម្រេចគោលដៅបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) មួយរួមគ្នានៅឆ្នាំ២០១៥។ ក្នុងនេះកម្ពុជា ត្រូវធានាថាគ្រប់ប្រទេសជាសមាជិក ត្រូវអនុវត្តឲ្យបានតាមផែនទីបង្ហាញផ្លូវសម្រាប់សហគមន៍អាស៊ានឆ្នាំ២០០៩-២០១៥ ក្រោមទិសស្លោកថា "អាស៊ានសហគមន៍តែមួយ វាសនាតែមួយ"។

ផែនទីបង្ហាញផ្លូវ ចែងថា ប្រទេសជាសមាជិកត្រូវអនុវត្តឲ្យបានលើ ១១១ កំណែទម្រង់គោលនយោបាយ ដែលជាផ្នែកមួយនៃដំណាក់កាលដំបូងក្នុងការអនុវត្ត AEC (២០០៨-២០០៩) ប៉ុន្តែជាមធ្យមប្រទេសជាសមាជិកនីមួយៗអនុវត្តបានត្រឹមតែ ៨៣,៨% ប៉ុណ្ណោះ។ ដំណាក់កាលទី២ នៃផែនទីបង្ហាញផ្លូវ (២០១០-២០១១) តម្រូវឲ្យប្រទេសនីមួយៗអនុវត្ត ១៨៩ វិធានការបែថមទៀត ប៉ុន្តែជាមធ្យមអនុវត្តបានតែ ៦៨,៦០% ប៉ុណ្ណោះ។ ដូច្នេះ កម្ពុជាត្រូវខំជំរុញឲ្យមានការចូលរួមកាន់តែប្រសើរក្នុងកិច្ចប្រឹងប្រែងដ៏សំខាន់បំផុតនេះ ។

កម្ពុជា ក៏ត្រូវជំរុញតួនាទីកាន់តែធំសម្រាប់វិស័យឯកជនក្នុងការធ្វើគោលនយោបាយ និងដំណើរការរបស់អាស៊ាន ហើយត្រូវប្រើប្រាស់ឲ្យបានកាន់តែប្រសើរនូវអត្ថប្រយោជន៍នៃ FTA របស់អាស៊ាន និងទំនាក់ទំនងសហប្រតិបត្តិការ និងពាណិជ្ជកម្មទ្វេភាគី។

តួអង្គក្នុងវិស័យឧស្សាហកម្មក្នុងទូទាំងតំបន់ ត្រូវតែកៀរគរឲ្យបានតាមរយៈក្រុមឧស្សាហកម្មដ៏សមស្របតាមប្រទេសនានា ដើម្បីបំពេញតួនាទីឲ្យកាន់តែសកម្ម ក្នុងការបង្កើតស្តង់ដាររួម បទបញ្ញត្តិផ្នែកបច្ចេកទេស និងតម្រូវការវាយតម្លៃផ្សេងៗទាំងផ្ទៃក្នុងអាស៊ាន និងរវាងអាស៊ាន និងបណ្តាដៃគូក្នុង FTA។

ការរួបរួមគ្នា និងភាពចុះសម្រុងក្នុងចំណោមសមាជិក គឺជាមូលដ្ឋានគ្រឹះសម្រាប់អាស៊ាន។ ដូច្នេះ គួរប្រឹងប្រែងកាន់តែខ្លាំងទៀតដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងអាស៊ាន និងប្រទេសមានកម្រិតលូតលាស់ទាបជាង ដូចជា កម្ពុជា ឡាវ និង មីយ៉ាន់ម៉ា តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក។

ដំណើរការនៃវេទិកាតំបន់អាស៊ាន អាស៊ាន+៣ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ផ្តល់ឱកាសដ៏ល្អសម្រាប់ការជំរុញកិច្ចសហប្រតិបត្តិការសន្តិភាព និងសន្តិសុខក្នុងតំបន់ ការបង្ការទំនាស់ ការដោះស្រាយភាពតានតឹង ក៏ដូចជាការគោរព និងការពារផលប្រយោជន៍របស់ប្រទេសទាំងតូចទាំងធំនៅក្នុងតំបន់។ ដៃគូរបស់អាស៊ាន និងប្រទេសដទៃទៀតក្នុងតំបន់ គួរជួយគាំទ្រមីយ៉ាន់ម៉ាឲ្យសម្រេចបំណងប្រាថ្នា និងបំពេញបានតាមតួនាទីដ៏ត្រឹមត្រូវរបស់ខ្លួនក្នុងអាស៊ាន។

កិច្ចសហប្រតិបត្តិការអាស៊ាន ក៏សំខាន់បំផុតដែរសម្រាប់ដោះស្រាយបញ្ហាសង្គមនៅក្នុងតំបន់។ កម្ពុជា ត្រូវរំលឹកពួកប្រទេសជាសមាជិកអំពីការប្តេជ្ញាចិត្តរបស់ពួកគេ ក្នុងការកាត់បន្ថយភាពក្រីក្រស្របតាមធម្មនុញ្ញអាស៊ាន លើកកម្ពស់គោលការណ៍មិនឲ្យរីករាលដាលអាវុធនុយក្លេអ៊ែរ ប្រឆាំងអំពើភេរវកម្ម ប្រឆាំងការជួញដូរមនុស្ស និងដោះស្រាយការគំរាមកំហែងពិតៗនៃការផ្លាស់ប្តូរអាកាសធាតុ។

អាស៊ាន គួរដើរតួនាទីកាន់តែសកម្មឡើងក្នុងបញ្ហាអន្តរជាតិផ្សេងៗ។ តួនាទីនេះ ត្រូវមានការប្តេជ្ញាចិត្តពីសំណាក់បណ្តាប្រទេសជាសមាជិក និងធនធានកាន់តែប្រសើរ ព្រមទាំងតួនាទីកាន់តែធំនៃអគ្គលេខាធិការ និងលេខាធិការដ្ឋានអាស៊ាន និងការបន្តវេណកាន់តែរលូនល្អពីប្រធានមួយទៅប្រធានមួយទៀត។

កម្ពុជា តែងជាអ្នកគាំទ្រដ៏មោះមុតនៃភាពតភ្ជាប់គ្នាចុះឡើងក្នុងតំបន់ និងបានអនុវត្តកំណែទម្រង់ភាគច្រើន ដើម្បីគោរពតាមផែនទីបង្ហាញផ្លូវឆ្នាំ២០១៥ របស់សហគមន៍សេដ្ឋកិច្ចអាស៊ានដោយបំពេញបានដល់ទៅ ៩៥,៣៣% នៃកំណែទម្រង់ដែលតម្រូវឡើងសម្រាប់ដំណាក់កាលទី១ និង ៧៦,៣០% សម្រាប់ដំណាក់កាលទី២។ លទ្ធផលទាំងពីរនេះ មានកម្រិតខ្ពស់ច្រើន បើធៀបនឹងមធ្យមភាគក្នុងអាស៊ាន។

បញ្ហាប្រឈមជាក់ស្តែងមួយសម្រាប់កម្ពុជា គឺការអភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីអនុវត្តគោលនយោបាយឲ្យមានប្រសិទ្ធភាព និងតម្លាភាព។ ស្របពេលដែលអាស៊ានក្លាយជាទីផ្សារតែមួយ ហើយលំហូរទំនិញ សេវាកម្ម និងប្រជាជនក៏កើនឡើង សមត្ថភាពនេះកាន់តែសំខាន់ខ្លាំង បើសិនចង់ឲ្យបណ្តាញផ្ទៃក្នុងតំបន់ ជួយជំរុញសេដ្ឋកិច្ចកម្ពុជាបានច្រើនបំផុត។ ដូច្នេះ ការកសាងសមត្ថភាពស្ថាប័នផ្តោតចំគោលដៅជាការងារខានមិនបានមួយ សម្រាប់ជោគជ័យក្នុងរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជា នៅក្នុង AEC។

វេណជាប្រធានអាស៊ាន ពិតជាផ្តល់ឱកាសឲ្យកម្ពុជាអាចជះឥទ្ធិពលវិជ្ជមាន និងយូរអង្វែងទៅលើស្ថាប័ននេះ។ ចក្ខុវិស័យរបស់នាយក រដ្ឋមន្ត្រីកម្ពុជាសម្រាប់អាស៊ានគឺ អង្គការមួយដ៏រឹងមាំ មានសមាជិកប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ហើយមានធនធាន និងរចនាសម្ព័ន្ធអង្គការចាត់តាំងកាន់តែប្រសើរ។ ការផ្លាស់ប្តូរទាំងនេះ នឹងជួយឲ្យអាស៊ានចូលរួមចំណែកបានកាន់តែសក្តិសិទ្ធិ នៅក្នុងរបៀបវារៈសាកលផ្សេងៗ ហើយតួនាទីនេះសំខាន់ខ្លាំងណាស់នៅក្នុងស្ថានភាពសេដ្ឋកិច្ចសាកលដ៏តឹងតែងនាបច្ចុប្បន្ន៕

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh